# ខ្លែងឯកក្នុងសង្គម វប្បធម៌ និងសិល្បៈ

ក្នុងសង្គមខ្មែរ "ខ្លែង" មានសណ្ឋានច្រើនបែបយ៉ាងណាស់ អាស្រ័យទៅតាមគំនិត និងសិល្បៈច្នៃប្រតិដ្ឋបង្កើតឡើងប្រកបដោយចំណេះចេះតជំនាន់មក។ បើនិយាយត្រឹមតែខ្លែងសម្រាប់បង្ហើរជាល្បែងកម្សាន្តលេងម្តងម្កាល វត្ថុនោះសាមញ្ញធម្មតា ហើយក្មេងទូទៅនៅតាមស្រុកស្រែជនបទក៏អាចធ្វើសម្រាប់លេងដោយខ្លួនឯងបានដែរ ដ្បិតគេអាចយល់អំពីរបបខ្យល់បក់ កម្លាំងខ្យល់ និងទិសខ្យល់ជាដើម។ ប៉ុន្តែបើនិយាយចំពោះប្រភេទខ្លែងម្យ៉ាងហៅថា "ខ្លែងឯក" គឺមានលក្ខណៈពិសេសផ្សេងដោយឡែកក្នុងវប្បធម៌ខ្មែរ បើធៀបនឹងខ្លែងទូទៅធម្មតា ឬខ្លែងបរទេសនានា។ ពោលគឺខុសគ្នាលើផ្នែករូបរាង វិធីធ្វើ រដូវកាលលេង និងជាពិសេសគឺ ជំនឿ ព្រមទាំងប្រពៃណីជាប់នឹងខ្លែង។

ពាក់ព័ន្ធកំណើតខ្លែងឯកនេះ គ្មានឯកសារណាកំណត់ច្បាស់លាស់ ថាមានឡើងតាំងពីត្រឹមណាមកឡើយ ដ្បិតខ្លែងឯកអាចចាត់ទុកបានជាមត៌ក ដែលមានជីវិតជិតជាប់នឹងសង្គមខ្មែររាប់តំណាតមក។ ប៉ុន្តែក្នុងគ្រាខ្លះ គេអាចលើកការនិទានផ្សេងៗមករៀបរាប់បញ្ជាប់ចម្ងល់ពាក់ព័ន្ធនឹងកំណើតខ្លែងឯក។ ជាក់ស្តែងអ្នកខ្លះយល់ថារឿងធ្មញ្ជ័យ[1] ក៏ជាប្រវត្តិបង្កើតខ្លែងដែរ គ្រាដែលស្តេចស្រុកចិនចាប់ធ្មញ្ជ័យដាក់គុកសំរឹទ្ធ។ នៅក្នុងពេលនោះធ្មញ្ជ័យកើតប្រាជ្ញាធ្វើខ្លែងឯកបង្ហោះរាល់យប់ រហូតស្តេចចិនយល់ថាជាហេតុមិនល្អក្នុងនគរ ក៏បានដោះលែងធ្មញ្ជ័យវិញ។[2]

យោងឯកសាររបស់ព្រឹទ្ធាចារ្យ មៀច ប៉ុណ្ណ មានរឿងមួយនិទានថាមានព្រះរាជាមួយអង្គទ្រង់បានយកទង់ព្រលឹងរបស់ព្រះរាមដែលសោយទិវង្គត ទៅធ្វើជាខ្លែង បំណងឱ្យព្រលឹងរបស់ព្រះរាមបានទៅកើតនៅឋានសួគ៌។ ចំណែកនិទានមួយទៀតបានបង្ហាញដោយឡែកយ៉ាងដូច្នេះថា ដើមឡើយមានជនជាតិភាគតិចម្នាក់ឈ្មោះ កាលែងពោនង បានធ្វើខ្លែងឱ្យចៅលេងកម្សាន្ត។ ដោយពុំដឹងហៅឈ្មោះខ្លែងនោះយ៉ាងដូចម្តេច អ្នកស្រុក

---

[1] ឈ្មោះនេះឃើញសរសេរច្រើនបែបដូចជា "ធនញ្ជ័យ ឬ ធ្មេញជ្រៃ" ហើយខ្លះអានថា "ធ្មេញដៃ ឬធន់ដៃ"។

[2] សូមអាន៖ "រឿងធ្មជ្ជ័យ" បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៧២ ទំ.៥២-៥៤

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក៏ហៅតាមឈ្មោះតាម្ចាស់ខ្លែងនោះតែម្តង។ ចំណេរក្រោយមកសំនៀងអានថា "កាលែងពោនង" ក៏ក្លាយជា "ខ្លែងព្នង" ដែលជាឈ្មោះខ្លែងមួយបែបទៀតហៅសំដៅ "ខ្លែងឯក" (រូបលេខ១)។[3]



រូបលេខ១ ខ្លែងឯក ដែលអ្នកស្រុកស្រែជនបទនិយមបង្ហោះក្នុងរដូវច្រូតកាត់ហើយ (រូប៖ ?)

KHMER CIVILIZATION

តាមរយៈនិទានខាងលើស្តែងឱ្យឃើញថា ទោះបីពុំមានឯកសារជាក់លាក់បង្ហាញថាខ្លែងឯកកើតឡើងក្នុងសម័យណាក៏ដោយ តែខ្លែងឯកតែងស្ថិតក្នុងចិត្តអ្នកស្រុកជានិច្ចរៀងមក។ បើក្នុងព្រះរាជពិធីទ្វាទសមាស បានចអង្កុលឯកសារ៣ ពាក់ព័ន្ធនឹងព្រះរាជពិធីបង្ហើរខ្លែងប្រារព្ធនៅក្នុងខែមិគសិរ។ ឯកសារទី១ គឺ "ព្រះរាជពង្សាវតារប្រទេសកម្ពុជារជ្ជកាលព្រះបាទហរិរក្សរ(ព្រះបរមកោដ្ឋ)" របស់ឧកញ៉ាយោមរាជ ឈុន នៅវិជ្ជាស្ថានពុទ្ធ

[3] មៀច ប៉ុណ្ណ, ១៩៩៦, ទំ.៨៧-១០៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សាសនបណ្ឌិត លេខគ-២៨។ ឯកសារទី២ គឺ "ទំនៀមខ្មែរ" របស់ឧកញ៉ាវង្សាឧទ័យ អតីតចៅហ្វាស្រុកស្ទោង(កំពង់ធំ) និងឯកសារទី៣ គឺ "ព្រះរាជពិធីទ្វាទសមាស" របស់ឧកញ៉ាមហាមន្ត្រី ល្មុត ចាងហ្វាងក្រុមព្រះរាជមន្ទីរ ហើយដែលឯកសារទាំង៣នេះមានសេចក្តីថា ខែមិគសិរ បង្ហើរខ្លែងថ្វាយព្រះចូឡាមណីចេតិយ បញ្ចុះព្រះកេសធាតុឯស្ថានត្រៃត្រឹង្ស។[4]

តាមសៀវភៅពិធីប្រចាំដប់ពីរខែ នៅថ្ងៃពេញបូណ៌មី ខែមិគសិរ ពេលព្រឹកគេនិមន្តព្រះសង្ឃឆាន់ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ដល់វេលាយប់ ព្រះករុណា និងនាម៉ឺនសព្វមុខមន្ត្រីទ្រង់ធ្វើពិធីបង្ហើរខ្លែងថ្វាយចំពោះទេវតា។ ព្រះករុណា ឬរាជតំណាងទ្រង់យាងអុជគោមដែលចងភ្ជាប់នឹងតួខ្លែង ដែលមានព្រះសង្ហារជាសម្គាល់ផង រួចទើបគេលែងខ្លែងឲ្យអណ្តែតឡើងទៅលើអាកាសទាល់អជ្រាតទើបឈប់។ គេទាយដំណើរទឹកភ្លៀងនៅឆ្នាំមុខដោយយកដំណើរដែលខ្លែងហោះឡើងនេះ។[5] ប៉ុន្តែព្រះរាជពិធីនេះ គេពុំដឹងថាខកខានពុំបានប្រារព្ធតាំងពីសម័យណាមកឡើយ។ ទោះបីយ៉ាងណាក្តី ក្រោយសង្គ្រាមបានបញ្ចប់ចាប់ពីឆ្នាំ១៩៩៤ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានរៀបចំប្រារព្ធពិធីបង្ហើរខ្លែងទូទាំងប្រទេស ក្នុងគោលបំណងស្តារនិងថែរក្សាប្រពៃណី ទំនៀមទម្លាប់ជាតិ ឲ្យគង់វង្សរហូតដល់សព្វថ្ងៃ (រូបលេខ២-៣)។



រូបលេខ២ មហោស្រពបង្ហើរខ្លែងទូទាំងប្រទេស ឆ្នាំ១៩៩៥ (រូបថត៖ អ៊ុង រតនា)



រូបលេខ២ មហោស្រពបង្ហើរខ្លែងទូទាំងប្រទេស ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ

---

[4] ចាប ពិន, ១៩៦០, ទំ.១៣៧-១៨០

[5] ពេជ្រ សល់, ១៩៦៦, ទំ.៧៣-៧៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បច្ចុប្បន្នគេមើលឃើញថា ការធ្វើខ្លែងឯកពិបាកជាងខ្លែងធម្មតា ដ្បិតគេត្រូវធ្វើមានក្បួនខ្នាតត្រឹមត្រូវ គួបផ្សំនឹងទេពកោសល្យម្នាក់ៗ ដែលត្រូវយល់ពីទម្រង់ខ្លែង ការធ្វើឯក សិល្បៈរចនាលម្អលើខ្លែង និងយល់ពីជំនោរខ្យល់នៃរដូវបង្ហើរខ្លែងក្នុងស្រុកភូមិរបស់គេ។ ខ្លែងឯកដែលបុរាណនិយមធ្វើតែងមានទំហំធំៗ មានប្រវែងស្លាបទាំងសងខាងពី៣ ទៅ៤ម៉ែត្រក៏សឹងមានដែរ។ ចំពោះផ្នែកសំខាន់ៗនៃខ្លែងឯកបើរាប់ចុះពីលើមកក្រោមដូចជា ផ្នែកក្បាល (បំពាក់ឯក) ស្លាប ចង្កេះ កូន កន្ទុយទា ឬជើងទា និងភ្ជាប់ដោយកន្ទុយមួយគូយ៉ាងវែងនៅពេលបង្ហើរ (រូបលេខ២៨)។ អ្នកធ្វើខ្លែងឯក ត្រូវចេះលៃទំហំផ្ទៃខ្លែង បិតឬស្សីធ្វើឆ្អឹង ធ្វើកន្ទុយ ចាក់ខ្សែទ្រូង និងជាពិសេសបំផុតគឺការចេះធ្វើ "ឯក" ឱ្យមានសំឡេងពីរោះមិនស្អក។[6] ផ្ទៃខ្លែងគេអាចធ្វើពីក្រដាស ឬក្រណាត់ ឬប្លាស្ទិកក៏បាន ឆ្អឹងខ្លែងធ្វើពីឬស្សីចាស់ ទន់រលាស់មិនស្រួយបាក់។ ដងឯកធ្វើពីឬស្សី តែអណ្ដាតឯកអាចធ្វើពីផ្ដៅបិតឲ្យស្ដើង ឬបណ្ដូលស្លឹកត្នោត។ ដោយឡែក កន្ទុយខ្លែងឯកតែងមានមួយគូ ឬពីរគូ ដែលអាចមានប្រវែង ម្ខាងៗចាប់ជាង១០ ម៉ែត្រ ទៅ២០ម៉ែត្រ អាស្រ័យតាមទំហំខ្លែង ហើយអាចធ្វើពីស្លឹកត្នោត ឬស្លឹកទ្រាំងក៏កាន់ប្រសើរ (រូបលេខ២៩)។ សូមបញ្ជាក់ថា ខ្លែងឯកច្រើនតែមនុស្សចាស់ ឬមនុស្សពេញកម្លាំងជាអ្នកបង្ហើរ ដ្បិតក្មេងកម្លាំងពុំដល់ខ្លែងទេ។



រូបលេខ២៨ ការស្វែងយល់អំពីផ្នែកផ្សេងៗរបស់ខ្លែងឯក ដែលតាំងបង្ហាញនៅសារមន្ទីរខ្លែងខ្មែរ



រូបលេខ២៩ ខ្លែងឯកដែលបំពាក់កន្ទុយតាមក្បួនខ្នាតក្នុងពេលបង្ហើរ

[6] សូមអាន៖ អាំង ជូលាន, ២០១២, ១៤៤ និង ថាន់ មនោមយិទ្ធិ "ខ្លែងឯក" ផ្សាយលើគំណ https://ams.com.kh/khmercivilization/detail/310 ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមចំណាំនៅជនបទ អ្នកស្រុកច្រើនចាប់ផ្ដើមបង្ហើរខ្លែងវេលាទៀបភ្លឺ ដ្បិតពេលនោះជំនោរខ្យល់ស្មើល្អធ្វើឲ្យខ្លែងហោះបានខ្ពស់ មានលំនឹង ហើយបន្ទឺសំឡេងឯកបានពីរោះ។ មិនតែប៉ុណ្ណោះ គេអាចបង្ហើរចងខ្សែចោលមួយរយៈ រួចទៅធ្វើកិច្ចការអ្វីផ្សេងៗក៏សឹងបាន។ សព្វថ្ងៃក្រៅពីបង្ហើរលេងកម្សាន្តក្នុងរដូវលម្ហើយ ខ្លែងឯកតែងមានវត្តមានក្នុងកម្មវិធីតាមសហគមន៍ និងព្រឹត្តិការណ៍ខ្លែងថ្នាក់ជាតិ-អន្តរជាតិជាដើម(រូបលេខ២៦-២៧)។ លើសពីនេះ គេតែងសម្គាល់ឃើញខ្លែងឯកបច្ចុប្បន្នតែងរំលេចដោយក្បាច់រចនា ឬគំនូរផ្សេងៗ ជាអត្តសញ្ញាណរបស់សហគមន៍ ឬរបស់ក្រុមណាមួយ ឬរំលេចសារប្រវត្តិសាស្ត្រលើផ្ទៃខ្លែង (រូបលេខ២៨)។ ជាក់ស្ដែងថ្មីៗនេះ ក្រុមយុវជនខ្មែរមួយក្រុមបានរួបគ្នាបង្ហើរខ្លែងក្នុងន័យទាមទារសន្តិភាពសម្រាប់កម្ពុជា បានគូរភ្ជាប់នូវរូបភាពវីរកងទ័ពកម្ពុជាទាំង១៨រូប ដែលយោធាថៃចាប់ជាចំណាប់ខ្មាំងកាលពីខែកក្កដា ឆ្នាំ២០២៥ (រូបលេខ២៩)។



រូបលេខ២៦ បុណ្យបង្ហើរខ្លែងនៅស្រុកបន្ទាយស្រី ឆ្នាំ២០២១ (រូបថត៖ កែវ រចនា)



រូបលេខ២៧ ព្រឹត្តិការណ៍ Sky Fest នៅខេត្តព្រះសីហនុ ឆ្នាំ២០២៣ (រូបថត៖ កោះសន្តិភាព)





រូបលេខ២៨-៩ ការរចនាផ្ទៃខ្លែងភ្ជាប់នឹងខ្លឹមសារប្រវត្តិសាស្ត្រនៃសន្ធិសញ្ញាបារាំង-សៀម និងវីរកងទ័ព១៨នាក់ដែលយោធាថៃចាប់ជាចំណាប់ខ្មាំងកាលពីខែកក្កដា ឆ្នាំ២០២៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# អត្ថបទ៖ ខ្លែងឯកក្នុងសង្គម វប្បធម៌ និងសិល្បៈ

លើសពីអ្វីដែលរៀបរាប់ខាងលើ មួយរយៈចុងក្រោយនេះខ្លែងឯកក៏បានក្លាយទៅជាប្រធានបទនៃទម្រង់សិល្បៈរបាំ និងការតុបតែងរចនាបង្ហាញម៉ូតផងដែរ (រូបលេខ១០)។ ក្នុងឆ្នាំ២០២០ និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានដំឡើង "របាំខ្លែងឯក" ដឹកនាំដោយអ្នកគ្រូរបាំ ឈឹម ណាលីន ចូលរួមប្រឡងប្រជែងក្នុងទិវាវប្បធម៌ជាតិ លើកទី២២ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" និងទិវាសប្បុរសធម៌លើកទី១១។ របាំខ្លែងឯកនេះ ជាទម្រង់របាំប្រជាប្រិយបង្ហាញពីទិដ្ឋភាពអ្នកស្រែក្រោយរដូវច្រូតកាត់បោកបែន ជាពិសេសគឺការលេងបង្ហើរខ្លែង (រូបលេខ១១)។





រូបលេខ១០-១១ ការប្រើប្រាស់ប្រធានបទខ្លែងឯកក្នុងសិល្បៈម៉ូត និងរបាំប្រជាប្រិយ

សរុបខ្លីមក ខ្លែងឯកពិតជាមានអត្ថន័យជ្រៅក្នុងបរិបទវប្បធម៌ និងសង្គមខ្មែរ ដ្បិតឃើញអ្នកស្រុកអ្នកស្រែបន្តលេងហូរហែដល់បច្ចុប្បន្ន។ ក្នុងគំនិតអ្នកសិក្សាស្រាវជ្រាវខ្លះសំយោគថា ខ្លែងឯកក៏មានជំនឿជាប់នឹងរឿងអាកាសធាតុ ខ្យល់ និងភ្លៀងដែរ ដូចឃើញមានចែងខ្លះក្នុងទំនៀមព្រះរាជពិធីទ្វាទសមាសផង។ មិនតែប៉ុណ្ណោះ ក្នុងគំនិតថ្មីនៃការចូលរួមទ្រទ្រង់រក្សាខ្លែងឯក យុវជនជំនាន់ថ្មីផ្ដើមកែច្នៃទៅតាមទម្រង់សិល្បៈផ្សេងៗកាន់តែសម្បូរបែប៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ចាប ពិន,

១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ទំ.១៣៧-១៤០, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ថាន់ មនោមយិទ្ធិ

"ខ្មែរឯក" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/310 ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២០

ពេជ្រ សល់,

១៩៦៦, *ពិធីប្រចាំដប់ពីរខែ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

មៀច ប៉ុណ្ណ,

១៩៩៦, "ប្រវត្តិខ្មែរពួន ឬខ្មែរអែក និងប្រពៃណីបង្ហើរខ្មែរ", *កម្ពុជសុរិយា*, ឆ្នាំទី ៥០ លេខ៥, ទំ.៨៧-១០៥, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

អនាមិក

១៩៧២, *រឿងផ្កាញ្ញូយ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

អាំង ជូលាន

២០១២, "ខ្មែរឯក", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២៨, ទំ.១៤២, យសោធរ, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត